ការដាំដើមឈើជុំវិញផ្ទះ និងការថែទាំ

របៀបដាំដើមឈើឲ្យបានត្រឹមត្រូវ

1. ជ្រើសរើសទីកន្លែងដែលត្រូវដាំ ។
   នេះគឺជាការសម្រេចចិត្តដ៏សំខាន់!
   ត្រូវពិចារណាពី
   បរិមាណពន្លឺព្រះអាទិត្យដែលដើមឈើត្រូវ
   ការដើម្បីរស់ ក៏ដូចជាទំហំដើមឈើរបស់អ្នក
   ក្នុងរយៈពេល 20-30 ឆ្នាំ ខាងមុខ ។
2. យកដើមឈើចេញពីផើង ។
   ទាញគល់វាចេញ
   ដោយការសង្កត់គែមផើងស្រាលៗ ។
   កាត់ជ្រៀកយកសំបកផើងចេញ
   ដោយប្រើកន្ត្រៃយ៍ ។

3. កាត់តម្រឹមឫស ។
   យកកាំបិតមានផ្លែដូចធ្មេញរ
   ណាមកកាត់ឫសស្មាញនៅជុំវិ
   ញគល់ដែលមានដី
   និងកាត់ជាអក្សរ "X"
   នៅផ្នែកខាងក្រោមនៃគល់ដែល
   មានដី ។

   បន្ទាប់មកយកដៃរបស់អ្នកមក
   ច្របាច់ដីជុំវិញគល់
   ដើម្បីឲ្យឫសនៅខាងក្រៅ និងដី
   នៅជុំវិញគល់មានភាពធូរ ។
4. រកមើលឫសរីកធំចេញពីគល់ដោយផ្ទាល់ ។
   រកមើលបរិវេណដែលគល់វារីកធំ
   ហើយរីកចូលទៅកាន់ឫសរបស់វា ។
   ត្រង់នេះគេហៅថា ឫសធំចេញពីគល់ ។
5. ជីកររណ្តៅសម្រាប់ដាំដើមឈើ ។
   ជីកររណ្តៅដើម្បីដាំដើមឈើឲ្យបានទំហំពីរដ
   ងធំជាងដីជាប់គល់ និងឫសរបស់វា
   ហើយជីកដីឲ្យរាក់ល្មម ដើម្បី
   ដាក់ឫសធំចេញពីគល់ឲ្យខ្ពស់ជាងដី ។
6. លុបអាចម៍ដីរណ្តៅ ។
   ដាក់កូនឈើចូលក្នុង
   រណ្តៅឲ្យចំកណ្តាលដោយថ្នមៗ
   ឲ្យដើមវាត្រង់ទៅលើ ។ ដាក់អាចម៍ដីចូលវិញ
   ដើម្បីលុបរណ្តៅ ។
   ទុកឲ្យឫសធំចេញពីគល់នៅពីលើដី!
7. ការដាក់ជីរកំប៉ុស្តុ៍កុំឲ្យដីហួតតាមរបៀប 3-3-3 ។
   ត្រូវយកជីរកំប៉ុស្តុ៍ស្រស់មកដាក់ជារង្វង់ជុំវិញ
   កូនឈើ របស់អ្នក ក្នុងទំហំ 3′ និងជម្រៅ 3″
   ។ ត្រូវដាក់ជីរកំប៉ុស្តុ៍ 3 អ៊ុិញ ឆ្ងាយពីគល់ឈើ
   ដើម្បីឲ្យឫសធំចេញពីគល់
   អាចប៉ះជាមួយខ្យល់ខាងក្រៅ ។
   ជីរកំប៉ុស្តុ៍ដែលអ្នកដាក់ជុំវិញគល់ឈើ
   ត្រូវមានរាងដូចជានំកងដូណាត់ ។
8. ស្រោចទឹក!
   ស្រោចទឹកកូនឈើដែលអ្នកទើបដាំរួច
   ចំនួនពី 15-20 ហ្គាឡន ។

របៀបថែទាំកូនឈើរបស់អ្នក

ស្រោចទឹក! រយៈពេលពីរឆ្នាំដំបូងក្រោយការដាំ ត្រូវស្រោចទឹកកូនឈើរបស់អ្នកពី 15-20 ហ្គាឡន **ចំនួនមួយដង**ក្នុងមួយសប្តាហ៍ ចាប់ពីខែមីនា ដល់ខែធ្នូ។ ត្រូវស្រោចទឹកយឺតៗ ហើយស្រោចចំកណ្តាលនៃរង្វង់ដីកំប៉ុស្តិ៍ ដើម្បីឲ្យទឹកអាចជ្រាបចូលក្នុងដីបានជ្រៅ ហើយឫសរបស់វាអាចបឺតយកទឹកបានជាបណ្តើរៗ ។ ប្រើទុយ៉ូ បង្ហូរទឹកជាតំណក់ៗ ចំនួនមួយម៉ោង បើអ្នកប្រើទុយ៉ូបង្ហូរទឹកបែបផ្កាឈូក ត្រូវបង្ហូរទឹកចំនួន 10 នាទី ឬក៏យកធុងមានចំណុះទឹក 5 ហ្គាឡន ចោះរន្ធខាងក្រោម បង្ហូរចូលក្នុងរណ្តៅកូនឈើរបស់អ្នក ។

ជីរកំប៉ុស្តិ៍ ។ ប្រើជីរកំប៉ុស្តិ៍ធ្វើពីចំណាំងឈើ សម្រាប់រៀបជារង្វង់ជុំវិញគល់កូនឈើ ដែលមានទំហំបីហ្វីត និងជម្រៅបីអ៊ិញ ។ ទុកចន្លោះពីគល់ឈើចំនួនបីអ៊ិញ ដើម្បីឲ្យបរិវេណគល់ជាប់ជាមួយឫសធំអាចទទួលបានខ្យល់អាកាស ។ ពេលរួចរាល់ហើយ ជីរកំប៉ុស្តិ៍ដែលអ្នកដាក់ព័ទ្ធជុំវិញគល់ឈើ ត្រូវមានរាងដូចជានំកងដូណាត់ ។ នៅរៀងរាល់ដើមរដូវផ្ការីក និងរដូវស្លឹកឈើជ្រុះស្លឹក ត្រូវដាក់ជីរកំប៉ុស្តិ៍ ជាថ្មីដល់ឈើរបស់អ្នក ។ អ្នកអាចសុំជីរកំប៉ុស្តិ៍ដោយមិនបាច់បង់ប្រាក់ពីមជ្ឈមណ្ឌលប្រើប្រាស់ធនធានសរីរាង្គឡើងវិញនៃឧទ្យានហ្វែរម៉ន់ (Fairmount Park Organic Recycling Center) ។

កាត់មែកងាប់ មែកដែលមានជំងឺ និងមែកដែលខូចខាតចោល ។

- រកមើលមែកងាប់ មែកដែលមានជំងឺ ឬមែកដែលបាក់នៃដើមឈើរបស់អ្នក ។ ប្រើរណាដៃ ឬកន្ត្រៃយ៍កាត់មែកឈើ ដើម្បីកាត់មែកឈើចេញដោយប្រុងប្រយ័ត្ន
- គឺកាត់ពីលើបរិវេណឡើងប៉ោងដែលជាកន្លែងដែលមែកជាប់ជាមួយនឹងដើម ។
- បើកន្លែងត្រូវកាត់ចេញវាខ្ពស់ មិនអាចឈរកាត់បានទេ សូមពិចារណាជួលអ្នកឯកទេសខាងដាំដុះកូនឈើដែលមានអាជ្ញាប័ណ្ណ ឲ្យធ្វើកិច្ចការនេះវិញ

ឈើហូបផ្លែ

ត្រូវបេះផ្លែចោលក្នុងអំឡុងពេលពីរឆ្នាំដំបូង ។

- ត្រូវបេះផ្លែ មុនពេលវាទុំ ចោលឲ្យអស់ពីដើម ក្នុងអំឡុងពេលពីរឆ្នាំដំបូង ដើម្បីឲ្យដើមឈើអាចផ្តោតលើការចិញ្ចឹមឫសរបស់វាជាជាងការចិញ្ចឹមផ្លែ ។

បេះផ្លែចេញខ្លះក្នុងរដូវក្តៅ ។

- ដើម្បីអាចទទួលបានផលល្អជាង និងដើម្បីការពារការបាក់មែក ត្រូវបេះផ្លែវាចេញខ្លះ ដើម្បីឲ្យផ្លែដែលនៅសល់លើដើម មានគម្លាតពីគ្នារវាង 2”-5” ។